ចលនាខ្មែរដើម្បីប្រជាធិបតេយ្យ

**Khmer Movement For Democracy**

Organize the Movement * Educate the Public * Mobilize the People

០៤ មេសា ២០២៥

# ការពញ្ញាក់ស្មារតីពីការដំឡើងពន្ធ៤៩%របស់សហរដ្ឋអាមេរិក៖ កម្ពុជាចាំបាច់ត្រូវធ្វើកំណែទម្រង់

ចលនាខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ (KMD) មានការព្រួយបារម្ភយ៉ាងខ្លាំងទៅលើការដំឡើង ពន្ធនាំចូល៤៩% មកលើផលិតផលដែលនាំចូលពីប្រទេសកម្ពុជា ដោយរដ្ឋបាលប្រធានាធិបតី ដូណាល់ ត្រាំ និងទៅលើផលជះដែលអាចកើតឡើងទៅលើសេដ្ឋកិច្ច ទំនាក់ទំនងពាណិជ្ជកម្ម និង សិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា។ ទោះបីជាគោលនយោបាយរបស់រដ្ឋបាលប្រធានាធិបតី ដូណាល់ ត្រាំ នេះមានគោលដៅដោះស្រាយបញ្ហាវិសមភាព និងលើកកម្ពស់ឧស្សាហកម្មក្នុងស្រុករបស់ សហរដ្ឋអាមេរិកក្តី ប៉ុន្តែវានឹងមានផលជះអវិជ្ជមានយ៉ាងធ្ងន់ធ្ងរទៅលើសេដ្ឋកិច្ចរបស់ប្រទេសកំពុង អភិវឌ្ឍន៍ ដូចជាប្រទេសកម្ពុជាយើងជាដើម។

## ផលជះខាងផ្នែកសេដ្ឋកិច្ចសម្រាប់ប្រទេសកម្ពុជា

ប្រទេសកម្ពុជាពឹងផ្អែកទាំងស្រុងទៅលើការនាំចេញទៅសហរដ្ឋអាមេរិក ជាពិសេសការនាំ ចេញផលិតផលសម្លៀកបំពាក់ ស្បែកជើង សម្ភារធ្វើដំណើរ និងផលិតផលខាងវិស័យកសិកម្ម។ ការដំឡើងពន្ធនាំចូលរហូតដល់៤៩% នឹងនាំទៅដល់ការបង្អាក់សកម្មភាពនៃវិស័យទាំងនេះ ដោយ សារការឡើងថ្លៃយ៉ាងខ្លាំងនៃតម្លៃទំនិញកម្ពុជានៅក្នុងទីផ្សារសហរដ្ឋអាមេរិក។ ជាលទ្ធផល តម្រូវ ការសម្រាប់ការនាំចេញរបស់ប្រទេសកម្ពុជាអាចនឹងធ្លាក់ចុះ ដែលនាំទៅដល់ការបិទរោងចក្រ ការ បញ្ឈប់បុគ្គលិក និងអស្ថិរភាពផ្នែកសេដ្ឋកិច្ចសម្រាប់ពលកររាប់ម៉ឺននាក់។ សហគ្រាសធុនតូច និង មធ្យម (SMEs) ដែលពឹងផ្អែកលើពាណិជ្ជកម្មសកលក៏អាចទទួលរងការខាតបង់ផងដែរ ដែលធ្វើ ឲ្យមានវិសមភាពសេដ្ឋកិច្ចកាន់តែខ្លាំងឡើងថែមទៀត។

ជាងនេះទៅទៀត សេដ្ឋកិច្ចប្រទេសកម្ពុជាដែលបានងាយរងគ្រោះរួចមកហើយ ដោយសារ ការពឹងផ្អែកលើការវិនិយោគបរទេស និងកិច្ចព្រមព្រៀងពាណិជ្ជកម្មអនុគ្រោះ អាចជួបប្រទះនឹង ដំណើរថយក្រោយក្នុងរយៈពេលវែង។ ឧស្សាហកម្មកាត់ដេរដែលមានពលករប្រមាណ៩០០,០០០ នាក់—ភាគច្រើនជាស្ត្រី—អាចប្រឈមមុខនឹងបញ្ហាដែលមិនធ្លាប់មានពីមុនមក ធ្វើឱ្យភាពគ្មានការងារធ្វើ និងភាពក្រីក្រកើនឡើងកាន់តែធ្ងន់។ ភាពតានតឹងផ្នែកសេដ្ឋកិច្ចដែលបណ្តាលមកពីការ កាត់បន្ថយការនាំចេញក៏នឹងរារាំងដល់កិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញក្រោយជំងឺរាតត្បាតកូវីដ-១៩ របស់ប្រទេសកម្ពុជាផងដែរ។

សហគ្រាសធុនតូច និងមធ្យមនៅប្រទេសកម្ពុជា មានចំនួនប្រមាណ៧៥០,០០០កន្លែង បានរួមចំណែក៦៣%នៃផលិតផលក្នុងស្រុកសរុប និងផ្តល់ការងារ៧០%នៃកម្លាំងការងារសរុប។ ប៉ុន្តែសហគ្រាសជាច្រើននៅមិនទាន់បានចុះញ្ជី និងខ្វះលទ្ធភាពទទួលបានពលករជំនាញ។ ជាង ៨០% នៃការនាំចេញរបស់ប្រទេសកម្ពុជាពឹងផ្អែកលើវិស័យកាត់ដេរដែលមានប្រាក់ឈ្នួលទាប។

## ផលជះលើសិទ្ធិការងារ និងសិទ្ធិមនុស្ស

ការ ដំឡើង ពន្ធ សម្រាប់ផលិតផល កម្ពុជា មិន ត្រឹម តែ នាំ មក នូវ ផល ជះអវិជ្ជមានយ៉ាងខ្លាំងទៅ លើ ផ្នែកសេដ្ឋកិច្ច ប៉ុណ្ណោះ ទេ ប៉ុន្តែ ថែម ទាំងបង្កឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំងទៅ ដល់ សិទ្ធិ ការងារ និង សិទ្ធិ មនុស្សថែមទៀត។ កម្មកររោងចក្រ ជាពិសេសកម្មការិនី មានហានិភ័យបាត់បង់ ការងារ ដោយសារតែឱកាសការងារមានកាន់តែតិចជាងមុន និងកិច្ចការពារក្នុងវិស័យការងារបានធ្លាក់ចុះខ្សោយ។ ជាលទ្ធផល កម្មករជាច្រើនអាចទទួលរងគ្រោះដោយអំពើកេងប្រវ័ញ្ច និងការចូល បម្រើការងារក្រៅប្រព័ន្ធ ដែលមានលក្ខខណ្ឌការងារមិនមានសុវត្ថិភាព ប្រាក់ឈ្នួលទាប និងមាន ការងារមិនច្បាស់លាស់។ បញ្ហាប្រឈមទាំងនេះប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ស្ត្រីដែលបានប្រឈម មុខរួចទៅហើយជាមួយនឹងឧបសគ្គក្នុងការទទួលបានជំនាញ និងមុខតំណែងជាអ្នកដឹកនាំ ដោយ សារមានស្ត្រីជាអ្នកធ្វើការតិចជាង១% តែប៉ុណ្ណោះដែលកាន់មុខតំណែងជាអ្នកគ្រប់គ្រង ទោះបីជា ស្ត្រីមានចំណែកប្រមាណ៤៨.៤% នៃកម្លាំងការងារសរុបក៏ដោយ។

ជាងនេះទៅទៀត បញ្ហាប្រឈមសិទ្ធិមនុស្សដែលកំពុងបន្តកើតមានឡើងនៅប្រទេសកម្ពុជា រួមទាំងការដាក់កំហិតទៅលើសេរីភាព ការជ្រៀតជ្រែកនៅក្នុងប្រព័ន្ធតុលាការ និងការរំលោភសិទ្ធិ ដីធ្លី អាចនឹងកើតមានឡើងកាន់តែខ្លាំងឡើងថែមទៀត ដោយសារតែមានវិបត្តិសេដ្ឋកិច្ចដែលកើត ឡើងដោយការដំឡើងពន្ធ បានដាក់សម្ពាធបន្ថែមទៅលើរដ្ឋាភិបាល។ ក្នុងគ្រាមានវិបត្តិ ទំនោរនៃ អំពើផ្តាច់ការជារឿយៗកាន់តែមានស្ថានភាពអាក្រក់ទៅៗ ដែលនាំទៅដល់ការក្តោបក្តាប់អំណាច បន្ថែមទៀត និងមានការបង្កើនការគាបសង្កត់ទៅលើសហជីព អ្នកការពារសិទ្ធិមនុស្ស និងប្រព័ន្ធ ផ្សព្វផ្សាយឯករាជ្យ។ បរិយាកាសបែបនេះបានកើតឡើងដើម្បីទប់ស្កាត់បដិមតិ ក៏ដូចជារារាំងកិច្ច ខិតខំប្រឹងប្រែងក្នុងការដោះស្រាយការបំពានសិទ្ធិការងារ និងការរំលោភសិទ្ធិមនុស្ស។

ក្នុងបរិបទនេះ ផលជះអវិជ្ជមាននៃការដំឡើងពន្ធនេះនឹងលាតសន្ធឹងហួសពីវិស័យសេដ្ឋកិច្ច ទៅទៀត ធ្វើឱ្យបញ្ហាវិសមភាពផ្នែកយេនឌ័រ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការគាបសង្កត់ សេរីភាពស៊ីវិល មានសភាពកាន់តែធ្ងន់ធ្ងរឡើង។ នៅពេលដែលប្រទេសជាតិត្រូវប្រឈមនឹងបញ្ហា ប្រឈមចម្រុះទាំងនេះ វានឹងបង្កការរាំងស្ទះទៅដល់ការអភិវឌ្ឍរយៈពេលវែងរបស់ប្រទេសជាតិ និងមិនអាចប្រើប្រាស់បានពេញលេញនូវសក្តានុពលនៃកម្លាំងពលកម្មរបស់ខ្លួន ជាពិសេសកម្លាំង ពលកម្មរបស់ស្ត្រី។

## ឥទ្ធិពលរបស់ចិន និងឧត្តមភាពប្រៀបធៀបក្នុងវិស័យកសិកម្ម

ការដំឡើងពន្ធនេះនឹងធ្វើឲ្យប្រទេសកម្ពុជាកាន់តែពឹងផ្អែកផ្នែកសេដ្ឋកិច្ចទៅលើប្រទេសចិន ដែលបាននិងកំពុងពង្រីកឥទ្ធិពលរបស់ខ្លួនក្នុងតំបន់ តាមរយៈការវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធ ការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងការផ្តល់ជំនួយសេដ្ឋកិច្ច។ ជាមួយនឹងការកាត់បន្ថយការនាំ ចេញផលិតផលរបស់ខ្លួនទៅកាន់ទីផ្សារសហរដ្ឋអាមេរិក កម្ពុជាអាចនឹងសម្លឹងមើលអំពីការពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចរបស់ខ្លួនជាមួយប្រទេសចិន ដោយបង្កើនការពឹងផ្អែកទៅលើហិរញ្ញប្បទាន និងការកសាងភាពជាដៃគូពាណិជ្ជកម្មរបស់ចិន។ ទោះជាយ៉ាងណាក៏ដោយ ការផ្លាស់ប្តូរនេះអាច ធ្វើឱ្យប៉ះពាល់ទៅដល់អភិបាលកិច្ចប្រជាធិបតេយ្យ និងសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា ដោយ សារតែប្រទេសចិនតែងតែផ្តល់អាទិភាពទៅលើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ច្រើនជាងសេរីភាព នយោបាយ។

លើសពីនេះ ឧត្តមភាពនៃការប្រកួតប្រជែងរបស់ប្រទេសកម្ពុជាក្នុងវិស័យកសិកម្ម ជាពិសេស ដំណាំស្រូវ និងដំណាំស្បៀងផ្សេងទៀត អាចត្រូវបានបំផ្លាញដោយសារការដាក់ពន្ធរបស់សហរដ្ឋ អាមេរិក ដែលធ្វើឲ្យការនាំចេញរបស់ខ្លួនមានការប្រកួតប្រជែងតិចតួចតែប៉ុណ្ណោះ។ ប្រទេសចិន ដែលជាកម្លាំងដ៏លេចធ្លោក្នុងការធ្វើពាណិជ្ជកម្មផ្នែកកសិកម្ម អាចចាប់យកឱកាសនេះដើម្បីបង្កើន ការនាំចេញ និងការវិនិយោគរបស់ខ្លួននៅប្រទេសកម្ពុជា។ ខណៈពេលដែលការធ្វើបែបនេះអាច ជួយសម្រួលដល់ដំណើរការសេដ្ឋកិច្ចក្នុងរយៈពេលខ្លីក៏ដោយ ក៏ប៉ុន្តែ វាក៏អាចនាំឱ្យមានការពឹងផ្អែក ទាំងស្រុងទៅលើទីផ្សារប្រទេសចិន ធ្វើឱ្យប្រទេសកម្ពុជាមិនអាចមានសមត្ថភាពធ្វើពិពិធកម្មនៃ ទំនាក់ទំនងពាណិជ្ជកម្មរបស់ខ្លួនជាមួយបណ្តាប្រទេសនានា និងមិនអាចទទួលបាននូវលក្ខខណ្ឌ អំណោយផលសម្រាប់ប្រទេសខ្លួនឡើយ។ ប្រសិនបើប្រទេសចិនគ្រប់គ្រងបានទៅលើខ្សែច្រវាក់ ផ្គត់ផ្គង់កសិកម្មដ៏សំខាន់នៅកម្ពុជា កសិករខ្មែរអាចប្រឈមមុខនឹងការបណ្តេញចេញពីដីធ្លី និងការ ទន្ទ្រានយកដីធ្លីតាមទំនើងចិត្ត ការគ្រប់គ្រងតម្លៃកសិផល និងកាត់បន្ថយអំណាចចរចា។ ការព្រួយ បារម្ភនេះត្រូវបានលេចឡើងមានភាពជាក់ស្តែង ដោយសារផ្ទៃដីប្រមាណ២.១លានហិកតាត្រូវបាន
ផ្តល់ជាដីសម្បទានសេដ្ឋកិច្ច (ប្រភព៖ អង្គការលីកាដូ)។ ស្ថានភាពទាំអនេះបានធ្វើឱ្យចុះខ្សោយនូវ ឯករាជភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងបង្កឱ្យមានភាពចលាចលក្នុងសង្គម។

## អប្រសិទ្ធភាពរដ្ឋបាលសាធារណៈ និងអសមត្ថភាពស្ថាប័ន

រដ្ឋបាលសាធារណៈរបស់ប្រទេសកម្ពុជា បន្តប្រឈមមុខនឹងបញ្ហានៃភាពគ្មានប្រសិទ្ធភាព មានភាពបែកខ្ញែក និងមានអាណត្តិត្រួតស៊ីគ្នា ដែលធ្វើមានសម្ពាធកាន់តែខ្លាំងឡើងៗនៅក្នុងបរិបទ នៃវិបត្តិសេដ្ឋកិច្ចដែលជះឥទ្ធិពលពីខាងក្រៅ ដូចក្នុងករណីនៃការដំឡើងពន្ធរបស់សហរដ្ឋអាមេរិក ជាដើម។ រចនាសម្ព័ន្ធការិយាធិបតេយ្យដ៏ស្មុគស្មាញរបស់ប្រទេស—ដោយមានក្រសួង និងស្ថាប័ន ជាច្រើនដែលមានទំនួលខុសត្រូវត្រួតស៊ីគ្នា—បានធ្វើឱ្យខូចខាតដល់សមត្ថភាពរបស់រដ្ឋាភិបាលក្នុង ការឆ្លើយតបរហ័ស និងជាប់ជាប្រចាំ ទៅលើការរំខាននានាផ្នែកសេដ្ឋកិច្ច។ ក្រសួងដែលទទួល ខុសត្រូវលើពាណិជ្ជកម្ម ការងារ និងការអភិវឌ្ឍសេដ្ឋកិច្ច តែងតែដំណើរការដាច់ដោយឡែកតែឯង មិនចេះសហការគ្នា ដែលនាំឱ្យមានភាពមិនស៊ីសង្វាក់គ្នានៃគោលនយោបាយ និងការឆ្លើយតប យឺតយ៉ាវ។ ដូចគ្នានេះដែរ ភ្នាក់ងារដែលត្រួតពិនិត្យលើវិស័យកសិកម្ម ធនធានធម្មជាតិ និងកិច្ច ការពារបរិស្ថាន ជារឿយៗតែងមិនចេះសម្របសម្រួលជាមួយគ្នា នាំទៅដល់អប្រសិទ្ធភាពនៃកិច្ច ខិតខំប្រឹងប្រែងរួមគ្នាដើម្បីជួយដោះស្រាយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅជនបទ និងការ ប្រើប្រាស់សក្តានុពលកសិកម្មដើម្បីអភិវឌ្ឍន៍ប្រទេសជាតិ។

នៅពេលដែលសម្ពាធសារពើពន្ធកើនឡើងដោយសារតែការថយចុះនៃប្រាក់ចំណូលដែលបានមកពីការនាំចេញ និងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល ការរក្សាទុកនូវក្បាលម៉ាស៊ីន រដ្ឋបាលដ៏សំពោងសម្ពាយ អាចប៉ះពាល់ដល់ធនធានសាធារណៈថែមទៀត។ រចនាសម្ព័ន្ធរដ្ឋាភិបាល ដែលគ្មានប្រសិទ្ធភាពមិនត្រឹមតែរារាំងទៅលើការបង្កើតគោលនយោបាយដែលមានលក្ខណៈឆ្លើយ តបប៉ុណ្ណោះទេ តែថែមទាំងរួមចំណែកដល់កង្វះទំនុកចិត្តជាសាធារណៈ និងធ្វើឱ្យសមត្ថភាពរបស់ រដ្ឋចុះខ្សោយ មិនអាចកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលសេដ្ឋកិច្ចពិភពលោក រួមទាំងការប៉ះ ទង្គិចផ្នែកពាណិជ្ជកម្មដែលបណ្ដាលមកពីដំឡើងពន្ធផងដែរ។

## ភាពពឹងផ្អែកផ្នែកពាណិជ្ជកម្ម និងភាពងាយរងគ្រោះចំពោះភាពតក់ស្លុតពីខាងក្រៅ

ការពឹងផ្អែកយ៉ាងខ្លាំងរបស់កម្ពុជាលើទីផ្សារនាំចេញដ៏តូចចង្អៀត ជាពិសេសទីផ្សារសហរដ្ឋ អាមេរិក បានបង្កើតភាពងាយរងគ្រោះជាប្រព័ន្ធ កើតឡើងយ៉ាងច្បាស់ដោយសារការដំឡើងពន្ធ ៤៩%នេះ។ ការប្រមូលផ្តុំការនាំចេញក្នុងវិស័យមួយចំនួនតូចដូចជាសម្លៀកបំពាក់ ស្បែកជើង និង ផលិតផលកសិកម្ម គួបផ្សំនឹងភាពមានកម្រិតនៃការធ្វើពិពិធកម្មដៃគូពាណិជ្ជកម្ម ធ្វើឱ្យសេដ្ឋកិច្ចប្រទេសកម្ពុជាមានភាពងាយរងគ្រោះជាមួយនឹងផ្លាស់ប្តូរគោលនយោបាយពីខាងក្រៅ។ ភាពពឹង ផ្អែកទាំងស្រុងនេះបានរារាំងដល់សមត្ថភាពរបស់ប្រទេសកម្ពុជាក្នុងការទប់ទល់ជាមួយនឹងភាពតក់ ស្លុតផ្នែកសេដ្ឋកិច្ច កាត់បន្ថយភាពធន់របស់ខ្លួន និងដាក់ដែនកំណត់ទៅលើជម្រើសផ្សេងៗ នៅ ពេលដែលលទ្ធភាពទទួលបានទីផ្សារមានដែនកំណត់។

ជាងនេះទៅទៀត បើទោះបីជាប្រទេសកម្ពុជាមានទំនាក់ទំនងពាណិជ្ជកម្មរួចមកហើយ ជាមួយអាស៊ាន និងប្រទេសចិនក៏ដោយ ក៏ការពឹងផ្អែកខ្លាំងពេករបស់ប្រទេសនេះទៅលើដៃគូ មួយចំនួនតូចនោះបានបង្កជាបញ្ហាប្រឈមនៅពេលមានការផ្លាស់ប្តូរភូមិសាស្ត្រនយោបាយ និង បម្រែបម្រួលទីផ្សារ។ វិស័យដែលកំពុងលេចធ្លោរ ដូចជាថាមពលបៃតង បច្ចេកវិទ្យា និងនិរន្តរភាព ទេសចរណ៍នៅតែមិនទាន់អភិវឌ្ឍ ដោយធ្វើឱ្យរួមតូចនូវជម្រើសសេដ្ឋកិច្ចរបស់ប្រទេសនៅពេល ត្រូវប្រឈមមុខនឹងការរំខានផ្នែកពាណិជ្ជកម្ម។ បើគ្មានផលប័ត្រពាណិជ្ជកម្មដែលមានតុល្យភាព និងមានភាពចម្រុះជាងនេះទេ ប្រទេសកម្ពុជានឹងនៅតែប្រថុយជាមួយនឹងភាពជាប់គាំងរយៈពេល វែង អំណាចចរចាចុះខ្សោយ និងបង្កើនការពឹងផ្អែកលើដៃគូពាណិជ្ជកម្មដ៏មានឥទ្ធិពលដែលមិនផ្តល់ អាទិភាពទៅលើសិទ្ធិសេរីភាពផ្នែកនយោបាយ និងសិទ្ធិមនុស្សទាល់តែសោះ។

## អនុសាសន៍គោលនយោបាយ

ដើម្បីកាត់បន្ថយផលប៉ះជះអវិជ្ជមាននៃការដំឡើងពន្ធ៤៩% មកលើប្រទេសកម្ពុជា KMD ជំរុញឱ្យរដ្ឋាភិបាលកម្ពុជាចាត់វិធានការជាយុទ្ធសាស្ត្រជាច្រើន ដើម្បីឆ្លើយតបទៅនឹងការដំឡើង ពន្ធ៤៩% ដែលកំណត់ដោយរដ្ឋបាលសហរដ្ឋអាមេរិក ដូចខាងក្រោម៖

១. ចូលរួមក្នុងការចរចារការទូត – កម្ពុជាគួរចូលរួមពាក់ព័ន្ធយ៉ាងសកម្មភាពជាមួយមន្ត្រីរដ្ឋការ សហរដ្ឋអាមេរិក និងអ្នកតំណាងផ្នែកពាណិជ្ជកម្ម ដើម្បីស្វែងរកការលើកលែង ឬការបន្ធូរបន្ថយបន្ទុក ពន្ធ សម្រាប់វិស័យមួយចំនួន ដូចជាវិស័យកាត់ដេរ និងកសិកម្ម។ កិច្ចសន្ទនាការទូតគួរតែបញ្ជាក់ អំពីតួនាទីរបស់ប្រទេសកម្ពុជាក្នុងខ្សែច្រវាក់ផ្គត់ផ្គង់សកល និងផលប៉ះពាល់នៃការដំឡើងពន្ធទៅ លើពលករទូទៅ។

២. ពង្រឹងកិច្ចខិតខំប្រឹងប្រែងធ្វើពិពិធកម្មពាណិជ្ជកម្ម – ដើម្បីកាត់បន្ថយការពឹងផ្អែកទៅលើ ទីផ្សារសហរដ្ឋអាមេរិក ប្រទេសកម្ពុជាគួរតែពន្លឿនកិច្ចព្រមព្រៀង និងភាពជាដៃគូពាណិជ្ជកម្ម ជាមួយបណ្តាប្រទេសអាស៊ាន សហភាពអឺរ៉ុប ជប៉ុន កូរ៉េខាងត្បូង និងទីផ្សារដែលកំពុងលេចធ្លោរ នានានៅទ្វីបអាហ្វ្រិក និងអាមេរិកឡាទីន។ ការពង្រឹងទំនាក់ទំនងតាមរយៈភាពជាដៃគូសេដ្ឋកិច្ច គ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) និងក្នុងក្របខណ្ឌពាណិជ្ជកម្មផ្សេងទៀតក្នុងតំបន់ អាចផ្តល់នូវ គោលដៅទីផ្សារនាំចេញ។

៣. ស្វែងរកការស្តារឡើងវិញនូវកម្មវិធី «អ្វីគ្រប់យ៉ាងលើកលែងតែសព្វាវុធ» (EBA) របស់សហភាពអឺរ៉ុប – ប្រទេសកម្ពុជាគួរតែផ្តល់អាទិភាពដល់កំណែទម្រង់គោលនយោបាយ ជាពិសេសទៅលើសិទ្ធិការងារ និងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ដើម្បីស្តារឡើងវិញនូវ លទ្ធភាពទទួលបានភាពអនុគ្រោះដល់ទីផ្សារសហភាពអឺរ៉ុប។ ការដាក់ឱ្យដំណើរការឡើងវិញនូវ កម្មវិធី EBA នឹងជួយកាត់បន្ថយផលប៉ះជះអវិជ្ជមានផ្នែកសេដ្ឋកិច្ច ដែលជាផលវិបាកបណ្តាលមក ពីការបាត់បង់លទ្ធភាពចូលទៅកាន់ទីផ្សារសហរដ្ឋអាមេរិក។

៤. ពង្រឹងកំណែទម្រង់រដ្ឋបាលសាធារណៈ – ដើម្បីបង្កើនប្រសិទ្ធភាព និងភាពធន់ ប្រទេស កម្ពុជាគួរតែពង្រឹងសមត្ថភាពក្រសួង ស្ថាប័នរបស់រដ្ឋាភិបាល ដោយកាត់បន្ថយបែបបទការិយាធិប តេយ្យដ៏ស្មុគស្មាញ ក្នុងវិស័យពាណិជ្ជកម្ម ការងារ និងគោល នយោបាយសេដ្ឋកិច្ច។ ការរួមបញ្ចូល គ្នានៃក្រសួង ស្ថាប័នដែលពាក់ព័ន្ធគ្នាអាចនឹងលើកកម្ពស់ការសម្របសម្រួលគោល នយោបាយ និង ភាពឆ្លើយតបផ្នែកសេដ្ឋកិច្ច។

៥. ជំរុញឧស្សាហូបនីយកម្មក្នុងស្រុក និងផលិតកម្មដែលមានតម្លៃបន្ថែម – ជំនួសឱ្យការ ពឹងផ្អែកតែទៅលើការផលិតដែលមាន តម្លៃទាប ប្រទេសកម្ពុជាគួរតែវិនិយោគលើឧស្សាហកម្មដែល ផ្តល់តម្លៃបន្ថែម ដូចជាការកែច្នៃផលិតផលកសិកម្ម បច្ចេកវិទ្យា និង និរន្តរភាពនៃផលិតកម្ម។ ការ លើកទឹកចិត្តសម្រាប់ធុរកិច្ចក្នុងប្រទេស និងអ្នកវិនិយោគិនបរទេសក្នុងវិស័យទាំងនេះ អាចកាត់ បន្ថយភាពងាយរងគ្រោះចំពោះគោលនយោបាយពាណិជ្ជកម្មក្រៅប្រទេស។

៦. ស្តារឡើងវិញនូវសេរីភាពពលរដ្ឋ និងអនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាល និង សហជីពចូលរួមក្នុងការតាក់តែងគោល នយោបាយ – កិច្ចការពារសេរីភាពពលរដ្ឋ រួមទាំង សេរីភាពក្នុងការបញ្ចេញមតិ ការជួបប្រជុំ និងការបង្កើតសមាគម គឺជាកត្តា ចាំបាច់សម្រាប់ការតស៊ូ មតិឯករាជ្យ។ អង្គការមិនមែនរដ្ឋាភិបាល សហជីពការងារ និងសង្គមស៊ីវិល ត្រូវតែចូលរួមក្នុងការ រៀបចំគោលនយោបាយ ជាពិសេសពាក់ព័ន្ធនឹងសិទ្ធិការងារ សិទ្ធិមនុស្ស និងសមភាពយេនឌ័រ។ ការធានាឱ្យមានតម្លាភាព និង គណនេយ្យភាពក្នុងការអនុវត្តគោលនយោបាយ នឹងនាំមកនូវការ ត្រួតពិនិត្យជាសាធារណៈ និងការអនុលោមទៅតាមស្តង់ដារសិទ្ធិ មនុស្សអន្តរជាតិ ជំរុញឱ្យមាន ប្រព័ន្ធអភិបាលកិច្ចមួយដែលមានលក្ខណៈប្រជាធិបតេយ្យនិងបរិយាប័ន្ន ដែលការពារប្រជាពលរដ្ឋ ទាំងអស់ ជាពិសេសពលករ និងស្ត្រី។

៧. ពង្រីកលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានការបណ្តុះបណ្តាលផ្នែក TVET និង STEM– កិច្ចការនេះអាចសម្រេចបាន តាមរយៈការបង្កើនឱកាសសម្រាប់ស្ត្រីក្នុងវិស័យដែលមានតម្រូវការ
ខ្ពស់ដូចជា វិស័យវិស្វកម្ម និងបច្ចេកវិទ្យា ដោយផ្តល់នូវគំនិតផ្តួចផ្តើមនានាទាក់ទងនឹងយេនឌ័រ ដូចជា៖ ការផ្តល់អាហារូបករណ៍ ការបង្វឹក និងការអភិវឌ្ឍន៍អាជីព និងការលើកទឹកចិត្តដល់ភាពជា ដៃគូក្នុងវិស័យទាំងនេះ ដើម្បីផ្តល់ការបណ្តុះបណ្តាលជាក់ស្តែង និងបង្ហាញផ្លូវឆ្ពោះទៅរកឱកាស
ការងារ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះនឹងជួយធ្វើពិពិធកម្មកម្លាំងពលកម្ម ផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងចូលរួមចំណែកដល់ សេដ្ឋកិច្ចដែលមានភាពច្នៃប្រឌិត និងមានជំនាញបន្ថែមទៀត។

៨. ពង្រីកកម្មវិធីគាំទ្រកម្លាំងពលកម្ម និងសហគ្រាសធុនតូច និងមធ្យម – រដ្ឋាភិបាលគួរ តែណែនាំកម្មវិធីជំនួយគាំទ្រនានា រួមទាំង ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដើម្បីបង្កើតជំនាញថ្មីៗ គំនិតផ្តួចផ្តើមផ្នែកមីក្រូហិរញ្ញវត្ថុ ដើម្បីជួយសម្រាប់ការចាប់ផ្តើមអាជីវកម្ម ខ្នាតតូច និងកិច្ចការពារ សង្គម ដើម្បីទប់ស្កាត់ការផ្លាស់ទីលំនៅក្នុងហេតុផលសេដ្ឋកិច្ច។ វិធានការទាំងនេះនឹងផ្តល់នូវការ គាំទ្រ យ៉ាងសំខាន់ក្នុងការជួយពលករឱ្យចេះផ្លាស់ប្តូរទៅរកឱកាសការងារថ្មី រក្សាបាននូវស្ថិរភាព ហិរញ្ញវត្ថុ និងកាត់បន្ថយផលប៉ះពាល់ នៃការផ្លាស់ទីលំនៅក្នុងហេតុផលសេដ្ឋកិច្ច។

**សេចក្តីសន្និដ្ឋាន**

អនាគត របស់ ប្រទេស កម្ពុជា ពឹងផ្អែកទៅ លើ ជម្រើស ដែល ប្រជាពលរដ្ឋត្រូវជ្រើសរើស នៅ ពេលនេះ។ នៅក្នុងគ្រា ដែលមាន ការ ប្រឈម ផ្នែក សេដ្ឋកិច្ច និង នយោបាយ វា ក៏ ផ្តល់នូវច្រកចេញ មួយឆ្ពោះទៅរកកាលានុវត្តភាពផងដែរ ។ តាមរយៈការ វិនិយោគទៅលើប្រជាពលរដ្ឋរបស់ខ្លួន ការ ផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងការទទួលយកភាពបើកចំហ និងគណនេយ្យភាព ប្រជា ពលរដ្ឋខ្មែរ អាចកសាងអនាគតមួយប្រកបដោយចីរភាព និងសេចក្តីថ្លៃថ្នូរ។

111 Fitchburg Rd, Ayer, MA 01432
contact@khmermovementfordemocracy.org
Khmermovementfordemocracy.org
+1 702 808 0337